# ក្រមសីលធម៌សម្រាប់បុគ្គលិក ដែលធ្វើការនៅមណ្ឌលចត្តាឡីស័ក ក្នុងអំឡុងពេលនៃការផ្ទុះជំងឺកូវីដ-១៩

## វិសាលភាពនៃការអនុវត្តក្រមសីលធម៌

ក្រមសីលធម៌នេះ រៀបចំសម្រាប់អ្នកផ្តល់សេវា អ្នកការពារសន្តិសុខ អ្នកស្ម័គ្រចិត្ត និងតួអង្គទាក់ទងផ្សេងទៀត មកពីស្ថាប័នពាក់ព័ន្ធនានា កំពុងដំណើរការមណ្ឌលចត្តាឡីស័ក ដែលជាវិធានការឆ្លើយតបបន្ទាន់ចំពោះវីរុសកូវីដ-១៩។ ភាគីពាក់ព័ន្ធទាំងអស់ មានភារកិច្ចផ្តល់ការថែ ទាំដល់ស្ត្រី បុរស ក្មេងស្រី និងក្មេងប្រុស ដែលរងផលប៉ះពាល់គ្រប់វ័យ មានសាវតាចម្រុះ មានសុវត្ថិភាព និងកាត់បន្ថយការព្រួយបារម្ភ និងជាអ្នកទទួលខុសត្រូវ ត្រូវធានាយ៉ាងណាឱ្យអ្នកដែលកំពុងធ្វើចត្តាឡីស័កទទួលបានសេវាប្រកបដោយសីលធម៌វិជ្ជាជីវៈ និងធានាឱ្យមានការគាំពារ គោរព ការពារសេចក្តីថ្លៃថ្នូរ ថៃក្សា និងលើកស្ទួយសិទ្ធិមនុស្សរបស់បុគ្គលគ្រប់រូប ទោះបីកំពុងបំពេញ ឬសំរាកពីភារកិច្ច។

## គោលការណ៍ដែលត្រូវប្រកាន់ខ្ជាប់ដូចខាងក្រោម៖

១. បុគ្គលិក និងអ្នកផ្តល់សេវាទាំងអស់ត្រូវយល់ថា ប្រជាជនដែលកំពុងនៅក្នុងទីកន្លែងចត្តាឡីស័ក មិនត្រូវចាត់ទុកជាមនុស្សដែលត្រូវបានដកហូតសេរីភាពឡើយ។

២. បុគ្គលិក និងអ្នកផ្តល់សេវាទាំងអស់ ត្រូវយល់ពីវិធានការបង្ការការចម្លងរោគ យល់ពីហានិភ័យនៃវីរុស កូវីដ-១៩ និងត្រូវទទួលបានការបណ្តុះបណ្តាល ព្រមទាំងទទួលបានការពិនិត្យតាមដានក្នុងការអនុវត្ត វិធានការការពារខ្លួន។

៣. បុគ្គលិក និងអ្នកផ្តល់សេវាទាំងអស់ត្រូវយល់ពីភាពខុសគ្នានៃយេនឌ័រ គោលគំនិតសំខាន់ៗដែលទាក់ទងនឹងអំពើហិង្សាផ្លូវភេទនិងយេនឌ័រ និងសេវាកម្មបញ្ជូនដែលចាំបាច់សម្រាប់ជនរងគ្រោះ។

៤. បុគ្គលិក និងអ្នកផ្តល់សេវាទាំងអស់ត្រូវគិតពិចារណាពីស្ថានភាព និងភាពងាយរងគ្រោះជាក់លាក់របស់កុមារ ដែលត្រូវបង្ខំឱ្យស្វែងរកសុវត្ថិភាពនៅកន្លែងផ្សេង ទៀត។

៥. បុគ្គលិកទាំងអស់ ជាពិសេសអ្នកផ្តល់សេវា ដូចជា អ្នកគ្រប់គ្រង អ្នកផ្តល់សេវាសង្គម និងអ្នកផ្តល់សេវាសុខភាព ត្រូវធានាឱ្យមានការផ្តល់ជំនួយ តាមបែបផែនដែលមានសុវត្ថិភាព ផ្តល់ការគោរព សេចក្តីថ្លៃថ្នូរ និងភាពងាយស្រួលក្នុងការទទួលបានសេវាស្មើភាពគ្នា រវាងស្ត្រី បុរស ក្មេងស្រី និងក្មេងបុស្រស្របតាមវ័យ សមត្ថភាព ជាតិពន្ធុ សាសនា ការអប់រំ ស្ថានភាពសេដ្ឋកិច្ច និន្នាការផ្លូវភេទ សញ្ជាតិ ស្ថានភាពចំណាកស្រុក អត្តសញ្ញាណយេនឌ័រ និងសាវតាចម្រុះផ្សេងទៀតខុសៗគ្នា។

៦. ប្រសិនបើមានកុមារដែលបំបែកពីគ្រួសារ ឬមិនមានឪពុកម្តាយ ឬគ្មានអ្នកមើលថៃ បុគ្គលិក និងអ្នកផ្តល់សេវាគួរតែធានាថា កុមារមានសិទ្ធិទទួលបានការគាំទ្រ និងជំនួយពីអ្នកផ្តល់សេវាសង្គម ដូចជាការជួបជុំជាមួយក្រុមគ្រួសារវិញជាដើម ដោយរាយការណ៍ទៅកាន់មន្ទីរសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទាខេត្ត ដែលជាជនបង្គោលសម្រាប់ករណីទាំងអស់នោះ។

៧. បុគ្គលិក និងអ្នកផ្តល់សេវាទាំងអស់ គួរប្រើប្រាស់ការអប់រំបែបចិត្តសាស្ត្រ/ការបញ្ជ្រាបការយល់ដឹង និងការពង្រឹងជាវិជ្ជមានសម្រាប់ការផ្លាស់ប្តូរអាកប្បកិរិយា។ អំពើហិង្សាគ្រប់រូបភាពក្នុង ទីចត្តាឡីស័កត្រូវហាមឃាត់។

៨. ការកេងប្រវ័ញ្ចផ្លូវភេទ និងរាល់ការរំលោភបំពានគ្រប់ទម្រង់ និងគ្រប់រូបភាពទាំងអស់ទៅលើបុគ្គលណាម្នាក់នៅទីចត្តាឡីស័ក ត្រូវបានហាមឃាត់ដាច់ខាត និងជាទង្វើខុសច្បាប់។ បុគ្គលិក និងអ្នកផ្តល់សេវាទាំងអស់ មិនគួរស្នើសុំ ឬទទួលយកសាគុណផ្ទាល់ខ្លួន ជាថ្នូរនឹងការអនុញ្ញាតឱ្យអ្នកណាម្នាក់ ចូលរួមក្នុងសកម្មភាព និង/ឬទទួលបានសេវាក្នុងមណ្ឌលចត្តាឡីស័កនោះឡើយ។

៩. មិនត្រូវធ្វើការលេបខាយផ្លូវភេទ ទៅដល់បុគ្គលណាម្នាក់ ដែលកំពុងស្នាក់នៅមណ្ឌលចត្តាឡីស័កនោះឡើយ។ សកម្មភាពផ្លូវភេទជាមួយកុមារ (ជនមានអាយុក្រោម ១៨ឆ្នាំ) ត្រូវបានហាមឃាត់ដោយច្បាប់ ដោយមិនគិតពីអាយុភាគច្រើន ឬអាយុនៃការយល់ព្រម។ ជំនឿខុសទាក់ទងនឹងអាយុរបស់កុមារមិនអាច ជាលេសយកមកការពារនោះទេ។

១០. ក្នុងករណីដែលបុគ្គលិកមានការព្រួយបារម្ភ ឬមានការសង្ស័យពាក់ព័ន្ធនឹងការរំលោភបំពាន ឬការកេងប្រវ័ញ្ចផ្លូវភេទ ឬការរំលោភបំពានក្នុងទម្រង់ផ្សេងទៀតដែលអាចប្រព្រឹត្តដោយបុគ្គលណាម្នាក់ បុគ្គលិកនោះគួររាយការណ៍ពីការព្រួយបារម្ភនេះតាមរយៈយន្តការរាយការណ៍ (ចាត់តាំងអ្នកគ្រប់គ្រងម្នាក់ ឬអ្នកសម្របសម្រួលម្នាក់នៅក្នុងកន្លែងចត្តាឡីស័ក ដើម្បីទទួលបន្ទុកទទួលការរាយការណ៍ពីអំពើហិង្សា ការរំលោភបំពាន និងការបៀតបៀតផ្លូវភេទ)។

១១. ត្រូវសម្របសម្រួលជាមួយអ្នកផ្តល់សេវាជួរមុខផ្សេងទៀត (សេវាសុខភាព/សង្គម) និងធ្វើតាមនីតិវិធីដែលមានស្រាប់សម្រាប់ការបញ្ជូន នៅតាមកន្លែងចត្តាឡីស័ក ប្រសិនបើស្ត្រីឬកុមារត្រូវបានរកឃើញថា មានការថប់បារម្ភ។ ផលប៉ះពាល់បន្ទាប់បន្សំនៃវីរុសកូវីដ-១៩ ដែលមានសក្តានុពលទាក់ទងនឹងការការពារកុមារ រួមមានសុខភាពផ្លូវចិត្ត និងបញ្ហាផ្លូវចិត្ត និងការកើនឡើងនូវអំពើហិង្សា។ បុគ្គលិកនៅក្នុងកន្លែងចត្តាឡីស័កមានតួនាទីសំខាន់ក្នុងការកំណត់អត្តសញ្ញាណអ្នកដែលត្រូវការជំនួយផ្នែកសុខភាពផ្លូវចិត្ត និងចិត្តសាស្ត្រ រួមទាំងជនរងគ្រោះនៃការរំលោភបំពាន។ អាចរកអ្នកប្រឹក្សាយោបល់បាន ចាប់ពីម៉ោង៨ព្រឹក ដល់ម៉ោង១០យប់ ៧ថ្ងៃក្នុងមួយសប្តាហ៍តាមរយៈខ្សែទូរស័ព្ទចំនួន ៣ដូច ខាងក្រោម៖

០១៧ ២២២ ៣៧២
០៨៩ ៦៦៦ ៣២៥
០៩៧ ៩១១១ ៩១៨

១២. អ្នកគ្រប់គ្រងនៅគ្រប់កម្រិតទាំងអស់ ត្រូវមានការទទួលខុសត្រូវខ្ពស់ ដើម្បីធានាការអនុវត្ត តាមក្រមសីលធម៌នេះ ក៏ដូចជាផ្តល់ការគាំទ្រ និងបង្កើតនូវប្រព័ន្ធដែលរក្សាបាន នូវបរិយាកាសអនុវត្តក្រមសីលធម៌នេះ។

១៣. ត្រូវចងក្រងជាឯកសារ និងរក្សាទុកដោយសុវត្ថិភាព និងធានាការសម្ងាត់សម្រាប់ព័ត៌មានស្តីពីការគ្រប់គ្រងករណី។

**ការបំពានក្រមសីលធម៌នេះ នឹងត្រូវចាត់ទុកថា ការប្រព្រឹត្តមិនត្រឹមត្រូវ និងត្រូវបានស៊ើបអង្កេតដើម្បីចាត់ការតាមផ្លូវច្បាប់។**

សហការជាមួយ៖ គាំទ្រដោយ៖